ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨៩

ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦

**សាលដីកា**

លេខ: ៩៧

ចុះថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ២០០៦

**នាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | វៀល មួន | ចៅក្រម |
| ៤- លោក | ស៊ិន ឌឹម | ចៅក្រមរបាយការណ៍ |
| ៥- លោក | យូរ ឧត្តរា | ចៅក្រម |
| អ្នកស្រី | សុផុន សុមានីកា | ក្រឡាបញ្ជី |

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៨៩ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ របស់តុលាការកំពូល ។

<u>**ចំចោទ:**</u> ផ្តល់សក្ខីភាពក្លែង និងសមគំនិតក្នុងអំពើក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ ក្រុងភ្នំពេញ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ បទល្មើសដែលមានបញ្ញត្តិអោយផ្តន្ទាទោសតាមមាត្រា៤៩. ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះគីម ហុង "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ របររកស៊ី យោធា ទីលំនៅសព្វថ្ងៃផ្ទះលេខ៩DE០ ផ្លូវ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះគីម ហួយ "រ" ម្តាយឈ្មោះ ស៊ីវ ប៊ុន "រ" ប្រពន្ធឈ្មោះស៊ឹង សុខា ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

២-ជនជាប់ចោទឈ្មោះ បេន សុខា "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបឹងកុក សង្កាត់បឹងកុក ស្រុកកំពង់សៀម ខេត្តកំពង់ចាម របររកស៊ីយោធា ទីលំនៅសព្វថ្ងៃផ្ទះជួល

៦១ BE፣ ផ្លូវ៣១០ សង្កាត់បឹងកេងកង II ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះបេន សន "ស" ម្តាយឈ្មោះ លិន ហួយ "រ" ប្រពន្ធឈ្មោះ ម៉ម ស៊ីដែត មានកូន០៣នាក់ ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

-មេធាវី : លោក លីម វណ្ណា និង លោក ស៊ុម ស៊ីថាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ឹង ផល្លា "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស ទីលំនៅសព្វថ្ងៃផ្ទះលេខ៦១ E០ ផ្លូវ១០៥ សង្កាត់បឹងកេងកង II ខណ្ឌចំការមន ក្រុងភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះចាំង ម៉េងស្រេង "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស ទីលំនៅសព្វថ្ងៃផ្ទះលេខ១១៤ E០ ផ្លូវព្រះសីហនុ សង្កាត់បឹងកេងកង I ខណ្ឌចំការមន ក្រុងភ្នំពេញ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជីវ ស៊ូគុយ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស ទីលំនៅសព្វថ្ងៃផ្ទះលេខ១៩ E០ ផ្លូវ៣២៨ សង្កាត់ទួលស្វាយព្រៃ I ខណ្ឌចំការមន ក្រុងភ្នំពេញ ។

-មេធាវី : លោក ខូវ ចន្ទា

-តាមពាក្យបណ្តឹងចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ របស់ឈ្មោះ អ៊ឹង ផល្លា. ចាំង ម៉េងស្រេង និង ជីវ ស៊ូគុយ ប្តឹងពីឈ្មោះស៊ីវ ប៊ុន. គីម ហុង. បេន សុខា. ចាំង សុធា. ធូ សឿន. ជៀម ឡុន និង ឡុង ឡុន ពីបទ ផ្តល់សក្ខីភាពក្លែង ដោយអះអាងថា កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥ ឈ្មោះស៊ីវ ប៊ុន និង គីម ហុង បានប្តឹងឈ្មោះ ធូ សឿន និង ជៀម ឡុន ពីបទ ក្លែងលិខិតផ្តល់សក្ខីភាពក្លែងក្លាយ និងលួចលក់អចលនវត្ថុទាក់ទងនឹងដីដែលមានទីតាំងនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយចោទប្រកាន់ថា ពួកខ្លួនជាអ្នកឃុបឃិត ។ ដែលការចោទប្រកាន់ដើម្បីមួលបង្កាច់ដូចខាងលើរបស់ឈ្មោះស៊ីវ ប៊ុន. គីម ហុង. បេន សុខា និង ចាំង សុធា ពុំពិតប្រាកដឡើយ គឺជាការមួលបង្កាច់ដោយបំពានឱ្យខ្លួនខូចប្រយោជន៍ ។ ពួកខ្លួនបានទិញដីពីឈ្មោះជៀម ឡុន និង ធូ សឿន ដែលមានទីតាំងស្ថិតនៅភូមិចំការឪឡឹក សង្កាត់កាកាប តាមកិច្ចសន្យាចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ជាកិច្ចសន្យាធ្វើឡើងចំពោះមុខមេធាវី និងគូភាគី ។ បានជាពួកខ្លួនយល់ព្រមទិញដីនេះ ដោយពួកខ្លួនឃើញមានសាលក្រមស្ថាពរលេខ៤១ "ឈ" ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ បញ្ជាក់ថា បានប្រគល់ដីទំហំ៧២.៩១៧ម$^{២}$ ដែលមានទីតាំងដូចខាងលើទៅឱ្យឈ្មោះធូ សឿន និង ជៀម ឡុន ។ ដោយចង់បញ្ជាក់អោយអស់ភាពមន្ទិល ពួកខ្លួនបានធ្វើលិខិតស្នើសុំអោយក្រសួងយុត្តិធម៌បានបញ្ជាក់ថា សាលក្រមលេខ៤១"ឈ" របស់តុលាការក្រុងភ្នំពេញបានអនុវត្តស្របតាមនីតិវិធីនៃច្បាប់ហើយ មិនអាចប្តឹងទាស់ ឬ ប្តឹងឧទ្ធរណ៍បន្តទៀតបានឡើយ ។ ក្រោយពីការទិញដីនេះរួចមក ពួកខ្លួនក៏បានលក់ដីនេះ ទៅឱ្យឈ្មោះជីវ ស៊ូគុយ. ឡាយ ហួរ. ជូរ ហួរ និង ស៊ូ ឆេង ដោយបានផ្ទេរ កម្មសិទ្ធទៅតាមនីតិវិធីច្បាប់រហូតដល់ស្ថាប័នមានសមត្ថកិច្ច បានចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលន វត្ថុលេខ ភព ០១៥៦៥ ឆ្ន០១៥០ និងលេខ ភព ០១៥៦៦ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ ទៅឱ្យឈ្មោះ ជីវ ស៊ូគុយ.ឡាយជុនហួរ

និង ស៊ូ ឆេង ប្រើប្រាស់តាមច្បាប់ ។

-បានឃើញដីកាសំរេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ១៣៨៤ តព្រ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច : មិនឃុំខ្លួនជាបណ្តោះអាសន្ន ឈ្មោះតឹម ហុង ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩D ផ្លូវ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ របររកស៊ីយោធា ប្រពន្ធឈ្មោះស៊ឹង សុខា "លែងលះ" មានកូន០១នាក់ ឪពុកឈ្មោះតឹម ហួយ "រ" ម្តាយឈ្មោះស៊ីវ ប៊ុន "រ" ទោសពីមុនគ្មាន ដែលត្រូវជាប់ចោទពីបទផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ ក្រុងភ្នំពេញ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ តាមមាត្រា៩៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សាមីជនត្រូវចូលខ្លួនមកតុលាការជាដរាប កាលបើមានដីកាកោះហៅពីតុលាការ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់លោក ខូវ ចន្ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងមិនសុខចិត្តពីដីកាសំរេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ១៣៨៤តព្រ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញដីកាសំរេចមួយទៀតលេខ៧២៩៩ តព្រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១-ទទួលពាក្យសុំចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ របស់លោកមេធាវី លឹម វណ្ណា និងលោក តឹម ហួយ សុំធានាកូនក្តី និងកូនបង្កើតឈ្មោះ តឹម ហុង និង បេន សុខា ឱ្យបាននៅក្រៅឃុំបណ្តោះអាសន្ន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសគតិច្បាប់ ។

២-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ តឹម ហុង ភេទប្រុស អាយុ៣១ឆ្នាំ និងឈ្មោះ បេន សុខា ភេទប្រុស អាយុ៤៤ឆ្នាំ តាមដីកាឃុំខ្លួនលេខ៩៩៩ អឃង និង ១០០០ អឃង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតទៅទៀត ។

៣-ទុកសិទ្ធឱ្យគូភាគីប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៧២ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ របស់លោក លឹម វណ្ណា មេធាវីការពារអោយជនជាប់ចោទ ប្តឹងមិនសុខចិត្តពី ដីកាសំរេចលេខ៧២៩៩ តព្រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា: រឿងនេះ គឺបណ្តាលមកពីឈ្មោះលឹម វេងស៊ីម ដែលជាអ្នកដើរតួពីមនុស្សម្នាក់ទៅជាមនុស្សម្នាក់ផ្សេងទៀត ដែលតុលាការកំពុងអង្កេតស្វែងរកហើយ ។ ដំណាក់កាលស៊ើបអង្កេតតុលាការរកឃើញថា ឈ្មោះ បេន សុខា ទើបតែស្គាល់ឈ្មោះ ស៊ីវ ប៊ុន ឆ្នាំ២០០៣ ដើម្បីខ្ចីប្រាក់ ដែលមិនឃើញថា មានការសមគំនិតទេ ដូច្នេះ

ការឃុំខ្លួនឈ្មោះបេន សុខា គឺអាចប៉ះពាល់ដល់សិទ្ធិសេរីភាពគេ ឯឈ្មោះគីម ហុង កូនរបស់ឈ្មោះស៊ីវ ប៊ុន នេះគឺស្គាល់ឈ្មោះបេន សុខា តាមរយៈការខ្ចីប្រាក់ ដូចនេះឈ្មោះគីម ហុង អាចពាក់ព័ន្ធនឹងការផ្តិតមេដៃជាសាក្សីជាមួយឈ្មោះលីម វ៉េងស៊ីម ដែលគប្បីអង្កេតបន្តវែងឆ្ងាយទៀត ដូច្នេះ ចំពោះឈ្មោះគីម ហុង គប្បីឃុំខ្លួនបន្តទៀត ។ រីឯលោកមេធាវីប្តឹងឧទ្ធរណ៍ រឿងមិនឃុំខ្លួនលើឈ្មោះគីម ហុង នោះ គឺមិនទាន់ឃើញមានភស្តុតាងនៅឡើយ តុលាការកំពុងអង្កេតរឿង សក្តិភាពក្លែងក្លាយ ដូចនេះសុំមិនឃុំខ្លួនលើឈ្មោះ គីម ហុង ក្នុងបទចោទនេះ ទុកជាបានការ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៣៥"ឈ"ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់លោកមេធាវីខូវ ចន្ថា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ របស់លោកមេធាវីលឹម វណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

៣-តម្កល់ដីកាសំរេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ១៣៨៤តព្រ ចុះថ្ងៃទី០៨ ខែមិថុនាឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៤-បដិសេធដីកាសំរេចលេខ៧២៩៩ត.ព្រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៥-អនុញ្ញាតិឱ្យឈ្មោះ

ក/-បេន សុខា ភេទប្រុស អាយុ៤៤ឆ្នាំ កើតនៅភូមិបឹងកុក សង្កាត់បឹងកុក ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នផ្ទះជួល៦១BE៊ សង្កាត់បឹងកេងកង II ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ បេន សន "ស" ម្តាយឈ្មោះលិន ហួយ "រ" ប្រពន្ធឈ្មោះម៉ម ស៊ីដែត មានកូន០៣នាក់ ។

ខ/-គីម ហុង ភេទប្រុស អាយុ៣១ឆ្នាំ កើតនៅសង្កាត់លេខ៣ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ៩ D សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុក ឈ្មោះគីម ហួយ "រ" ម្តាយឈ្មោះ ស៊ីវ ប៊ុន "រ" ប្រពន្ធឈ្មោះស៊ឹង សុខា ពីបទៈ សមគំនិតក្នុងអំពើក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៥ នៅក្រៅឃុំជាបណ្តោះអាសន្ន ។

៦-បង្គាប់ឱ្យអាជ្ញាធរមានសមត្ថកិច្ចដោះលែងឈ្មោះបេន សុខា និង គីម ហុង នេះចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះមិនត្រូវបានជាប់ឃុំឃាំងពីបទល្មើសអ្វីផ្សេងទៀតទេនោះ ។

៧-សាលដីកានេះមានប្រសិទ្ធិភាពអនុវត្តភ្លាម ទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។

៨-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ខូវ ចន្ថា កំបាំងមុខជនជាប់ចោទឈ្មោះ បេន សុខា, គឹម ហុង ចំពោះមុខមេធាវី លឹម វណ្ណា ។

-បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១៥៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ របស់លោក ខូវ ចន្ថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៣៥"ឈ" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ របស់លោក ខូវ ចន្ថា មេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញសារណាតប ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះគឹម ហុង និង បេន សុខា ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

១-តើម្ចាស់បណ្តឹងសាទុក្ខមានគុណសម្បត្តិក្នុងការប្តឹងសាទុក្ខដែរ ឬ ទេ ?

២-ការអនុញ្ញាតិឱ្យនៅក្រៅឃុំ តើធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់អ្នកប្តឹង និងប៉ះពាល់ដល់ការស៊ើបអង្កេតដែរ ឬ ទេ? ។ សូមឯកឧត្តមប្រធាន និងក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសំរេច ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាការពារ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ របស់លោក ខូវ ចន្ថា មេធាវីជាតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី ។

-បានស្តាប់ក្រឡាបញ្ជីអានសារណាតប ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះគឹម ហុង និង បេន សុខា ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ខូវ ចន្ថា មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការថា:

+ ខ្ញុំសូមបញ្ជាក់ថា តើដូចម្តេចដែលហៅថា គុណសម្បត្តិរបស់អ្នកប្តឹង ? ព្រោះតាមធម្មតា អ្នកប្តឹងត្រូវបានបាត់បង់ផលប្រយោជន៍របស់ខ្លួន អំពីរឿងអ្វីមួយហើយទើបប្តឹងរកផលប្រយោជន៍របស់ខ្លួនមកវិញ ។

+ ចំពោះសាលក្រមរដ្ឋប្បវេណីលេខ៤១"ឈ" ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៣ ដែល

ចូលជាស្ថាពរហើយ ទើបឈ្មោះជៀម ឡុន និង ធូ សឿន លក់ដីមួយកន្លែងឱ្យមកកូនក្តីខ្ញុំបាទ តាមកិច្ចសន្យាចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្របតាមច្បាប់ហើយៗ ក្នុងរឿងនេះដែលកូនក្តីខ្ញុំលក់បន្តឱ្យទៅឈ្មោះជីវ ស៊ូគុយ. ឡាយ ហួរ. ជូរ ហួរ. ស៊ូ ឆេង ក៏បានកាត់ផ្ទេរកម្មសិទ្ធិតាមផ្លូវច្បាប់តែម្តង ។ ទើបម្ចាស់កម្មសិទ្ធិក្រោយចាក់ដី ក៏លេចចេញឈ្មោះស៊ីវ ប៊ុន និងបក្សពួកប្រឌិតក្លែងលិខិតស្នាមមេដៃរបស់ លឹម វេងស៊ុម លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ហើយបង្កើតជាសាលក្រមកំបាំងមុខលេខ៩៤"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ កូនក្តីខ្ញុំប្តឹងទាស់សាលក្រមនោះ ដើម្បីធ្វើការស្រាវជ្រាវរកភស្តុតាងឱ្យបានច្បាស់លាស់ ដែលមានអគ្គស្នងការនគរបាលជាតិធ្វើការរកភស្តុតាងទាំងនោះឃើញថា :

+ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីរវាងឈ្មោះលឹម វេងស៊ុម និងឈ្មោះស៊ីវ ប៊ុន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ កើតឡើងកំឡុងឆ្នាំ២០០៤-២០០៥ ទេវិញទេ គ្មានឈ្មោះ លឹម វេងស៊ុម នៅកម្ពុជាឆ្នាំ២០០៣ ឡើយ ។

+ លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលថា លឹម វេងស៊ុម មានទីលំនៅសង្កាត់ទឹកល្អក់ មានផ្ទះលេខ៦៥អា នេះ គឺម្ចាស់ផ្ទះក៏បានបញ្ជាក់ថា ពុំមានឈ្មោះនេះទេ ។ ដូច្នេះ ការដែលឈ្មោះគឹម ហុង និង បេន សុខា យកលិខិតក្លែងដាក់បន្ទុកលើកូនក្តីខ្ញុំនោះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ។

+ ការដែលក្លែងលិខិតនេះ គឺព្រះរាជអាជ្ញាបានចោទប្រកាន់ឈ្មោះ គឹម ហុង និង បេន សុខា ឈ្មោះស៊ីវ ប៊ុន ពីបទ ក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ ដែលត្រូវទោសជាបទឧក្រិដ្ឋ ជាពិសេសលោកចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនផងដែរ ។

+ ការដែលតុលាការក្រុង ក៏ដូចសាលាឧទ្ធរណ៍សំរេចមិនឃុំខ្លួនជនល្មើសនោះ ដោយសំអាងថា ខ្ញុំបាទនេះ ជាមេធាវីប្តឹងឧទ្ធរណ៍នោះជារឿងដោយឡែកទេវិញ ។

+ បើនិយាយពីឈ្មោះលោក ជីវ ស៊ូគុយ ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ដូចនេះការប្តឹងធ្វើឱ្យប៉ះពាល់ ខាតបង់ពេលវេលា ផលប្រយោជន៍កូនក្តីរបស់ខ្ញុំសម្បើមណាស់ បើឱ្យឈ្មោះនោះ បាននៅក្រៅឃុំវិញ ឃើញថា ប្រាសចាកពីការផ្តន្ទាទោសបុគ្គលប្រព្រឹត្តបទឧក្រិដ្ឋ ។

+ កន្លងមកជនល្មើសនេះធ្លាប់គំរាមសាក្សីរបស់ ជៀម ឡុន. ធូ សឿន ដោយមានកាំភ្លើងខ្លី ធ្វើការគំរាមនៅនគរបាលទៀតផង ។ ចុះបើសាលក្រមចោទថា មានទោសហើយនោះ តើអ្នកណាទទួលខុសត្រូវ ?

+ ពិនិត្យស្នាមមេដៃ និងធ្វើកោសល្យវិច័យមានលក្ខណៈមនុស្សម្នាក់ផ្តិតមេដៃ ហើយយកមនុស្សដដែលហ្នឹង មកធ្វើកោសល្យវិច័យនោះ គឺថាត្រឹមត្រូវហើយ ពីព្រោះសមត្ថកិច្ច គេរកឃើញ

ថា ឈ្មោះ លឹម វេងស៊ុម មិនមែនជាមនុស្សតែមួយទេ ដោយចង្អុលបង្ហាញពីថ្ងៃ ខែ ឆ្នាំកំណើត គឺខុសគ្នាទាំងស្រុង ។

+ ចំពោះរឿងក្តីនេះ តុលាការក៏បានរកឃើញថា ជនល្មើសដែលបានក្លែងលិខិតនោះមានពិរុទ្ធភាពច្បាស់លាស់ហើយ ខ្ញុំបាទជាមេធាវីការពារឱ្យដើមបណ្តឹង សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាសំរេច ឃុំខ្លួនបន្តជៀសវាងឱ្យឈ្មោះ គឹម ហុង និង បេន សុខា នៅក្រៅឃុំ បង្កបញ្ហាបន្តបន្ទាប់ទៀត ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក លឹម វណ្ណា មេធាវីការពារឱ្យជនជាប់ចោទ នាពេលសវនាការថា :

+ ជាដំបូងឈ្មោះធូ សឿន, ជៀម ឡន, ចាន់ រតនា បានលក់ដីឱ្យឈ្មោះលាង ទ្រី ហើយលាង ទ្រីបានលក់ដីឱ្យឈ្មោះលឹម វេងស៊ុម នៅឆ្នាំ១៩៩៧ ។ ដល់ឆ្នាំ២០០៣ លឹម វេងស៊ុម លក់បន្តឱ្យឈ្មោះ ស៊ីវ ប៊ុន ដោយបានប្រគល់ប័ណ្ណកម្មសិទ្ធច្បាប់ដើមទាំងពីរ និងធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីមានប្រធានភូមិ.សង្កាត់ និង អភិបាលខណ្ឌ អ្នកប្រថាប់ត្រាផង ។

+ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៣ ឈ្មោះ ចាំង ម៉េងស្រេង និង អ៊ឹង ផល្លា ប្រឌិតរឿងឱ្យឈ្មោះធូ សឿន និង ជៀម ឡន ប្តឹងមកលោក គង់ សែត ទើបចេញជាសាលក្រមកំបាំងមុខលេខ ៩៤"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ប្រគល់ដីនោះទៅឱ្យឈ្មោះធូ សឿន និង ជៀម ឡន ឯឈ្មោះចាំង ម៉េងស្រេង និង អ៊ឹង ផល្លា ក៏ធ្វើជាទិញដីពីឈ្មោះ ធូ សឿន និង ជៀម ឡន រួចលក់ទៅឱ្យឈ្មោះជីវ ស៊ូគុយ ។

+ នៅខែតុលា ឆ្នាំ២០០៤ ឈ្មោះស៊ីវ ប៊ុន ប្តឹងតវ៉ាបែរជាលោកគង់ សែត ចោទថា ក្លែងលិខិតផ្ទេរសិទ្ធិ លឹម វេងស៊ុម ក៏ចាប់ ស៊ីវ ប៊ុន ឃុំខ្លួនតែម្តង ក្រោយពីបាននៅក្រៅឃុំវិញ ឈ្មោះស៊ីវ ប៊ុន ត្រូវបានតុលាការជំនុំជំរះប្រគល់ដីនោះ តាមសាលក្រមលេខ៩៤"ច" ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ហើយអ្នកទាំងបីនាក់ក៏បានសារភាពប្រគល់ដីនោះមកឱ្យឈ្មោះស៊ីវ ប៊ុន ថែមទាំងសុំដកបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍ទៀតផង ទើបសាលក្រមនោះចូលជាស្ថាពរ ។

+ ភាគី ចាំង ម៉េងស្រេង ប្តឹងសុំឱ្យតុលាការសំរេចឡើងវិញ តែបណ្តឹងនោះ ក៏បានសំរេចលើកបណ្តឹងចោល ។ ទើបមានការប្តឹងទាស់ និងការអនុវត្តសាលក្រម តែតុលាការពុំព្រម ទទួលយកឈ្មោះ ចាំង ម៉េងស្រេង ក៏ប្តឹងបន្តទៅនគរបាលក្រសួងមហាផ្ទៃចាប់ឈ្មោះ គឹម ហុង និង បេន សុខា ជាតំណាងឱ្យឈ្មោះ ស៊ីវ ប៊ុន រារាំងមិនឱ្យអនុវត្តសាលក្រមនោះ ។

+ ការដែលមេធាវីដើមបណ្តឹងចោទថា កូនក្តីខ្ញុំបាទមានអាវុធគំរាមកំហែងសាក្សីកូនក្តីគាត់នោះ មិនពិតប្រាកដទេ ព្រោះអាវុធជារបស់អង្គភាព គ្មាននៅនឹងខ្លួនកូនក្តីខ្ញុំទេ ។ ជាពិសេសរឿងទាំងអស់នេះ សាលាឧទ្ធរណ៍បានពិចារណា អង្កេតច្បាស់លាស់ហើយ មិនមានអ្វីធ្វើឱ្យរាំងស្ទះនៃការសំរេច

ដែរ ហេតុនេះ ខ្ញុំបាទសូមបដិសេធនូវកាសែ្សតថតសម្លេង ពីព្រោះបច្ចុប្បន្ននេះ ការថតសំលេងអាចបញ្ចូលដោយវិធីណាក៏បានដែរ នេះបង្កឱ្យតុលាការមានការច្របូកច្របល់ប៉ុណ្ណោះ និងសូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

–បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ស៊ុម ស៊ីថាន មេធាវីការពារជនជាប់ចោទ នាពេលសវនាការថា :

+ ការដែលពាក់ព័ន្ធរឿងនេះ កើតឡើងពីបញ្ហាឃុំ ឬ មិនឃុំខ្លួនប៉ុណ្ណោះ ខ្ញុំបាទក៏សូមឯកភាពលើសាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចហើយ ។

+ បើពិនិត្យមើលនៅក្នុងរឿងនេះ គឺប្តឹងគ្នាចុះឡើង ហើយឃុំទៅឃុំមកមិនចេះចប់ ។

+ បញ្ហាមួយទៀត ការប្តឹងសុទ្ធតែមានសិទ្ធិប្តឹងគ្រប់ភាគី គ្រាន់តែបណ្តឹងនោះ ត្រឹមត្រូវ ឬមិនត្រឹមត្រូវ អាស្រ័យលើតុលាការសំរេច ។

+ តាមនីតិវិធីរបស់តុលាការថ្នាក់ក្រោមចាត់ការកន្លងមកមិនបានត្រឹមត្រូវនៅឡើយ ។ ហើយជាក់ស្តែង កូនក្តីខ្ញុំបាទឃើញថា ពុំមានអ្វីជាកំហុសធំដុំដែរ ឯទីលំនៅសព្វថ្ងៃមានអាស័យដ្ឋានច្បាស់លាស់ មុខរបរត្រឹមត្រូវមិនធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាសំរេចតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួន ទុកនៅដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី. សារណារបស់ជនត្រូវចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ជនត្រូវចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥៣ ចុះថ្ងៃទី២៣ខែសីហា ឆ្នាំ២០០៦ របស់លោក ខូវ ចន្ថា មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មានភាពមិនប្រក្រតីជាច្រើនក្នុងការចាត់ការស៊ើបអង្កេតរឿងក្តីនេះ ដែលនាំអោយភស្តុតាងដាក់បន្ទុកមានភាពព្រាលំ ពុំអាចយកជាការបាន ដូច្នេះ ការអោយជនត្រូវចោទទាំងពីរនាក់នៅក្រៅឃុំជាបណ្តោះអាសន្នជាការត្រឹមត្រូវហើយ ។

-យល់ឃើញថា ការដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនាសវិនាការនេះ ថាគប្បីឃុំខ្លួនជនត្រូវចោទ តាមមាត្រា ១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពិព្រោះពុំទាន់មានភស្តុតាងបញ្ជាក់ពីព្យសនៈកម្ម ដែលកើតឡើងពីអំពើដែលអះអាងថា ជាអំពើល្មើសនោះឡើយ ។

-យល់ឃើញថា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី មិនបានចូលរួមនាសវិនាការនៅតុលាការកំពូលនេះទេ ប៉ុន្តែមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទបានមកចូលរួមសវិនាការនេះហើយ ដូច្នេះ តុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៣៥"ឈ" ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី កំបាំងមុខជនត្រូវចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១៥៣ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦ របស់លោកមេធាវី ខូវ ចន្ថា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៥"ឈ" ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៨៩ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ។